# ក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីផ្លាស់ប្តូរ ( Transformative )

ដោយបណ្ឌិត វង់ សំអូន
ជំនួយការខុទ្ទកាល័យរាជបណ្ឌិត្យសភាកម្ពុជា

ការរីកដុះដាលនៃក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរ បានកើតឡើងនៅក្នុងចន្លោះទសវត្សទី៨០ និង៩០ ដោយយោងលើហេតុផលសំខាន់ៗមួយចំនួនមានដូចជា៖ (១) មនុស្សម្នាក់ៗនៅក្នុងសង្គមបានចាប់ផ្តើមគិតពិចារណាឡើងលើវិធានច្បាប់ គោលការណ៍ បទបញ្ញាសារាចរ សេចក្តីណែនាំ ឬការប្រកាស់ផ្សេងៗដែលបានដាក់ឱ្យពួកគេអនុវត្ត ឬគោរពតាម ថាបានគាបសង្កត់ រំលោភបំពាន ខ្វះភាពយុត្តិធម៌ គំរាមកំហែង ឬប៉ះពាល់ផលប្រយោជន៍ និងសិទ្ធសេរីភាពរបស់ពួកគេ (២) វឌ្ឍនភាពសង្គម សេដ្ឋកិច្ច នយោបាយ បច្ចេកវិទ្យា បរិស្ថាន និងបម្រែបម្រួលតម្រូវការរបស់បុគ្គលម្នាក់ៗនៅក្នុងសង្គមដែលកត្តាទាំងអស់នោះបានជំរុញ ទាមទារ និងតម្រូវឱ្យមានការសិក្សាស្រាវជ្រាវដើម្បីស្វែងរកធាតុចូលក្នុងការអភិវឌ្ឍប្រទេសជាតិ បំពេញចំណុចខ្វះខាត បំពេញតម្រូវការរបស់មនុស្សនៅក្នុងសង្គម លើកកម្ពស់សិទ្ធសេរីភាព សមភាព តម្លាភាព ភាពត្រឹមត្រូវ ឬយុត្តិធម៌ និង (៣)កង្វះខាតការសិក្សាស្រាវជ្រាវទាក់ទងនឹងភាពអយុត្តិធម៌ ដែលបានកើតមានឡើងនៅក្នុងសង្គមដូចជា៖ការកេងប្រវ័ញ្ច ការគាបសង្កត់ជិះជាន់ ការប្រើប្រាស់អំណាច វិសមភាពនៅក្នុងការប្រើប្រាស់សិទ្ធសេរីភាព ពិការភាព អំពើផ្តាច់ការ ការគ្រប់គ្រង និងដឹកនាំប្រទេស ការរើសអើង គម្លាតរវាងភេទប្រុស និងភេទស្រីក្នុងការអនុវត្តតួនាទី ការប្រកាន់ពូជសាសន៍ អំបូរជាតិសាសន៍ ការបញ្ចេញមតិយោបល់ កង្វះខាតការយកចិត្តទុកដាក់លើភេទទីបី សិទ្ធសេរីភាពរបស់ស្ត្រី ជនជាតិភាគតិច ឬជម្លោះផ្សេងៗនៅក្នុងសង្គមជាដើម។ល។

ក្រុមទស្សវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរ ***បានប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះតែប៉ុណ្ណោះ*** (ការសិក្សារួមគ្នាដោយប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ និងគុណវិស័យ) ដើម្បីសិក្សាស្រាវជ្រាវ (១) ក្រុម ឬសហគមន៍គោលដៅដែលជាក្រុមត្រូវបានគេបោះបង់ចោល ត្រូវបានគេគាបសង្កត់ គំរាមកំហែង ឬមិនបានទទួលសិទ្ធស្មើភាពគ្នានៅក្នុងនាមជាពលរដ្ឋម្នាក់នៅក្នុងសង្គម (២) ការសិក្សាស្រាវជ្រាវពីវិសមភាពនៅក្នុងសង្គមដូចជា៖ ភេទ ពូជសាន៍ ជនជាតិភាគតិច ពិការភាព វណ្ណៈសង្គម និងភេទសម្ព័ន្ធ (៣) ការសិក្សាស្រាវជ្រាវទាក់ទងនឹងវិសមភាពនៃសកម្មភាពសង្គម និងនយោបាយ និង (៤) ការសិក្សាស្រាវជ្រាវពីមូលហេតុនៃការករកើតឡើងនូវអំពើគាបសង្កត់ ការជិះជាន់ ឬទំនាក់ទំនងនៃការប្រើប្រាស់អំណាច។

ឧទាហរណ៍ ប្រជាពលរដ្ឋនៅក្នុងតំបន់ដាច់ស្រយ៉ាល នៅតាមតំបន់ភ្នំ ឬប្រជាពលរដ្ឋភាគតិចមិនបាន ឬបាត់បង់ឱកាសនៅក្នុងការទទួលសេវាកម្មអប់រំឱ្យបានពេញលេញដូចប្រជាពលរដ្ឋដែលបានរស់នៅទីប្រជុំជននៅក្នុងក្រុងនៅតាមខេត្តនីមួយៗ ឬនៅរាជធានីជាដើម។ល។ ក្នុងករណីនេះ អ្នកសិក្សាស្រាវជ្រាវអាចបង្កើតការសិក្សាស្រាវជ្រាវដើម្បីស្វែងយល់អំពី វិសមភាពនៃការទទួលការសិក្សា

អប់រំនៅក្នុងចំណោមសិស្សមតេយ្យសិក្សា នៅតាមតំបន់ដាច់ស្រយ៉ាលមួយចំនួនក្នុងប្រទេសកម្ពុជា។ យោងតាមបញ្ហានៃការសិក្សាស្រាវជ្រាវនេះ គេអាចកំណត់បានថា បញ្ហានេះមានទំនោរទៅរកក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីផ្លាស់ប្តូរ ដោយប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះក្នុងការស្វែងរកដំណោះស្រាយ ឬរកធាតុចូលដើម្បីធ្វើការកែប្រែ និងជំរុញឱ្យទទួលបានភាពស្មើរភាពគ្នានៅក្នុងការទទួលការអប់រំ។

ឧទាហរណ៍ គេសង្កេតឃើញថា នៅក្នុងការកាន់ដំណែងធំៗនៅក្នុងជួររាជរដ្ឋាភិបាលភាគច្រើនជាបុរស (ស្រ្តីមានចំនួនតិចតួចបំផុត)។ នៅត្រង់ចំណុចនេះបានបង្ហាញឱ្យឃើញពីគម្លាតតម្លាភាព សិទ្ធសេរីភាព និងទំនួលខុសត្រូវរវាងបុរស និងស្ត្រីនៅក្នុងការបម្រើការងារ ក៏ដូចជាការទទួលតួនាទីនៅក្នុងការងាររាជការ។ ក្នុងករណីនេះ អ្នកសិក្សាស្រាវជ្រាវអាចយកបញ្ហានេះ "សិទ្ធសេរីភាព តម្លាភាព និងទំនួលខុសត្រូវរបស់ស្ត្រីនៅក្នុងការបម្រើការងាររាជការ" ធ្វើជាប្រធានបទដើម្បីសិក្សាស្រាវជ្រាវស្វែងយល់ និងរកធាតុចូលក្នុងការធ្វើឱ្យគម្លាតរវាងបុរស និងស្ត្រីកាន់តែខិតចូលជិតគ្នា ឬជំរុញឱ្យមានភាពស្មើរគ្នារវាងបុរស និងស្ត្រីនៅក្នុងសង្គម។ តាមរយៈប្រធានបទនេះ បានបង្ហាញពីទំនោរទៅរកក្រុមទស្សនវិទូដែលនិយមការសិក្សាស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរ តាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះ។

ឧទាហរណ៍ នៅក្នុងសង្គមមួយចំនួន គេពុំសូវបានចាប់អារម្មណ៍ ឬឱ្យតម្លៃជនពិការតាមរយៈសកម្មភាពផ្ទាល់ ឬមិនផ្ទាល់ណាមួយ។ ដូច្នេះ អ្នកសិក្សាស្រាវជ្រាវអាចលើកយកបញ្ហានេះ "ការលើកកម្ពស់តម្លៃជនពិការនៅក្នុងសង្គម" ធ្វើការសិក្សាស្រាវជ្រាវដើម្បីរកធាតុចូលក្នុងការជួយជំរុញ និងលើកកម្ពស់តម្លៃជនពិការឱ្យមានភាពស្មើរគ្នាដូចមនុស្សទូទៅនៅក្នុងសង្គម។ យោងតាមធម្មជាតិនៃបញ្ហានេះ បានបង្ហាញពីទំនោរទៅរកក្រុមទស្សនវិទូដែលនិយមការសិក្សាជ្រាវដើម្បីបង្កើតការផ្លាស់ប្តូរដោយធ្វើឡើងតាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះ។

ជារួម រាល់បញ្ហាសិក្សាស្រាវជ្រាវទាំងឡាយណាដែលបានផ្តោតលើនយោបាយ ការប្រើប្រាស់អំណាច ភាពយុត្តិធម៌ ភាពអយុត្តិធម៌ ការស្វែងរកប្រយោជន៍រួម ឬការជំរុញឱ្យមានការផ្លាស់ដោយវិជ្ជមាន។ល។ *បញ្ហាទាំងអស់នោះ មានទំនោរទៅរកក្រុមទស្សនវិទូដែលនិយមការសិក្សាស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរ តាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះតែប៉ុណ្ណោះ។*

**តារាងទី១៖ ធាតុគោលរបស់ក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីផ្លាស់ប្តូរ**




## ឯកសារយោង

Babbie, E. (1995). The practice of social research (7th Ed.). Wadsworth publishing, California, USA

Creswell, W.J., & Creswell, D.J. (2018). Research Design: Qualitative, quantitative, and mixed methods approach. (5th Ed.). SAGE publication

Cronk, C.B. (2008). How to use SPSS: A step-by-step guide to analysis and interpretation. (5th Ed.). Pyrezak publishing, California, USA

Kerlinger, N.F. & Lee, B.H. (2000). Foundation of behavioral research (4th Ed.). Thomson learning, USA